**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០២៦/៣.១៦អអក

ភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈលើគម្រោងកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី សម្រាប់តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាល សម្រាប់ឆ្នាំ ២០១៦

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន **អ្នកប្រើប្រាស់អគ្គិសនី** ដែលឋិតនៅក្នុងដែនអាជ្ញាបណ្ណចែកចាយរបស់អគ្គិសនីកម្ពុជា នៅរាជធានីភ្នំពេញ និងនៅក្រុងតាខ្មៅ ខេត្តកណ្តាល ឲ្យបានជ្រាបថា យោងតាមការកំណត់នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី និងយោងតាមការពិនិត្យវិភាគថ្លៃអគ្គិសនីចែកចាយ ដែលបានធ្វើការគណនាក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ស្របទៅតាមគោលការណ៍កំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីគោលការណ៍វាយតម្លៃកាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី និងបទប្បញ្ញត្តិនានា អាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងនឹងកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា សម្រាប់ការលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅរាជធានីភ្នំពេញ និងនៅក្រុងតាខ្មៅ ខេត្តកណ្តាល តាមប្រភេទអតិថិជន និងអត្រាថ្លៃលក់អគ្គិសនី សម្រាប់ឆ្នាំ២០១៦ ដូចខាងក្រោម ៖

| **ប្រភេទ និងលក្ខខណ្ឌនៃការទិញ** | **អត្រាថ្លៃលក់** |
|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា នៅក្នុងតំបន់ចែកចាយភ្នំពេញ និងក្រុងតាខ្មៅ** | |
| ដែលប្រើមិនលើស ៥០ kWh ក្នុង ១ខែ | ៦១០រៀល ក្នុង១kWh |
| ដែលប្រើពី ៥១ ដល់ ២០០ kWh ក្នុង ១ខែ | ៧២០រៀល ក្នុង១kWh |
| ដែលប្រើលើសពី ២០០ kWh ក្នុង ១ខែ | ៧៨០រៀល ក្នុង១kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ និងលំនៅដ្ឋានរស់នៅរបស់ជនបរទេស** | |
| គ្រប់ទំហំប្រើប្រាស់ | ៧៨០រៀល ក្នុង១kWh |
| **៣.អតិថិជនមានលក្ខណៈរដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្ម ទាំងអស់** | |
| អតិថិជនធុនតូចទិញពីនាឡិកាស្ទង់តង់ស្យុងទាប ក្រោមបណ្តាញចែកចាយតង់ស្យុងទាប | ៧៨០រៀល ក្នុង១kWh |
| អតិថិជនធុនមធ្យមទិញពីនាឡិកាស្ទង់តង់ស្យុងទាប ក្រោមត្រង់ស្វូរបស់អគ្គិសនីកម្ពុជា | 0.1840$US ក្នុង១kWh |
| អតិថិជនធុនមធ្យមទិញពីនាឡិកាស្ទង់តង់ស្យុងទាប ក្រោមត្រង់ស្វូដែលខ្លួនវិនិយោគ | 0.1760$US ក្នុង១kWh |
| អតិថិជនធុនធំទិញពីនាឡិកាស្ទង់តង់ស្យុងមធ្យម ដែលដាក់នៅផ្នែកតង់ស្យុងមធ្យម | 0.1720$US ក្នុង១kWh |
| អតិថិជនធុនធំទិញពីនាឡិកាស្ទង់ ដែលដាក់នៅទ្វារចេញនៃតង់ស្យុងមធ្យមនៃអនុស្ថានីយ | 0.1545$US ក្នុង១kWh |

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាអាជ្ញាធរអគ្គិសនីកម្ពុជា សូមដាក់ "ឯកសារបញ្ជីថ្លៃលក់អគ្គិសនី" ថ្មីនេះ ពិគ្រោះយោបល់ជាសាធារណៈជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់អគ្គិសនីទាំងអស់ ដែលឋិតនៅរាជធានីភ្នំពេញ និងនៅក្រុងតាខ្មៅ ខេត្តកណ្តាល ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៦ ។ ក្រោយថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ "ឯកសារបញ្ជីថ្លៃលក់អគ្គិសនី" ថ្មីនេះនឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាព ឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកធ្វើសេវាកម្មចែកចាយ (អគ្គិសនីកម្ពុជា) ផង ។ ឯកសារគណនាបញ្ជីថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ **អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា** ............................................ សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់ទាំងអស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរីនៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ដល់អាជ្ញាធរអគ្គិសនីកម្ពុជាលើ "ឯកសារបញ្ជីថ្លៃលក់" ថ្មីនេះ មេត្តាជ្រាបជាព័ត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**



**អាជ្ញាធរអគ្គិសនីកម្ពុជា :** ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh